**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ០៤...ស.រ.ណ.ន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំខួបលើកទី៥៥ " ទិវាកុមារអន្តរជាតិ ១ មិថុនា និង ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា "

នៅក្នុងអំឡុងឆ្នាំ១៩៤២-៤៤ ពួកហ្វាស៊ីស្តអ៊ីត្លែបានបង្កអំពើវិនាសកម្មដ៏សែនឃោរឃៅ ដោយបានកាប់សម្លាប់ស្ត្រី និងកុមារ នៅភូមិលីឌីសែ ប្រទេសឆេក និងភូមិអូរ៉ាឌូប្រទេសបារាំង ។ វិនាសកម្មនេះបានបង្កើតនូវកំហឹងឈឺចាប់លើពិភពលោក ហើយសម័យប្រជុំសម្ព័ន្ធនារីអន្តរជាតិ នាឆ្នាំ១៩៤៩ បានឯកភាពកំណត់យកថ្ងៃ ១ មិថុនា រៀងរាល់ឆ្នាំជា "ទិវាកុមារអន្តរជាតិ" ។

នៅថ្ងៃ២០ វិច្ឆិកា ១៩៨៩ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ គោលដៅសកលលោកដើម្បីកុមារ ក៏ត្រូវបានអនុម័តដោយសន្និសីទកំពូលពិភពលោកដើម្បីកុមារ នាឆ្នាំ១៩៩០ ។ សម័យប្រជុំពិសេសស្តីពីកុមារនៃអង្គការសហប្រជាជាតិ នៅខែឧសភា ឆ្នាំ២០០២ និងលទ្ធផលនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីកុមារប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ឆ្នាំ២០០៣ នៅកោះបាលី បានកំណត់បញ្ហាអាទិភាព៤របស់កុមារគឺ : មរណៈភាពមាតា អាហារូបត្ថម្ភ មេរោគអេដស៍/ជម្ងឺអេដស៍ និងកិច្ចការពារ ។

ដោយឡែកនៅប្រទេសកម្ពុជា មហាវិនាសកម្មដែលបង្កឡើងដោយរបបប្រល័យពូជសាសន៍ប៉ុលពត បានធ្វើអោយប្រជាជន យុវជន កុមារ ក្លាយជាទាសករ រស់នៅយ៉ាងសែនវេទនា រងនូវទារុណកម្ម និងការកាប់សម្លាប់ដោយអយុត្តិធម៌រាប់លាននាក់ ។ ការងារកុមារ ត្រូវបានយកចិត្តទុកដាក់ ពិសេសចាប់តាំងពីក្រោយថ្ងៃ៧ មករា ១៩៧៩មក ។ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាបានលើកស្ទួយដល់សិទ្ធិទាំង៤របស់កុមារ ។ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ហើយនៅឆ្នាំ២០០២ បានផ្តល់សច្ចាប័នលើពិធីសារពីរគឺ : ការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារ ។

ដើម្បីបង្កើនកិច្ចគាំទ្រដល់កុមារកម្ពុជា ដែលជាអ្នកបន្តវេនប្រទេសជាតិឱ្យទទួលបាននូវសិទ្ធិកាន់តែល្អប្រសើរថែមទៀតនោះ ក្នុងឱកាសទិវាកុមារអន្តរជាតិ ១ មិថុនា ឆ្នាំ២០០៤ ខាងមុខនេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ:

១- ក្រសួង ស្ថាប័ន និង អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ត្រូវផ្សព្វផ្សាយជូនដល់អង្គភាពក្រោមឱវាទ និង សង្គមជាតិទាំងមូល បានជ្រួតជ្រាបអំពីប្រវត្តិទិវាកុមារអន្តរជាតិ និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា អនុសញ្ញា ឬ សេចក្តីប្រកាស អន្តរជាតិនានាដែលពាក់ព័ន្ធនឹងកុមារ និងរៀបចំកម្មវិធីជួបជុំសំណេះសំណាល និងមានការចាត់តាំងកំសាន្ត សប្បាយរបស់កុមារនៅក្នុងមូលដ្ឋានរបស់ខ្លួនទៅតាមលទ្ធភាពជាក់ស្តែង ។

២- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ សាលាក្រុងភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមិទ្ទិញព្យុះហយាត្រាកុមារ និង កម្មវិធីកំសាន្តផ្សេងៗសំរាប់កុមារ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៤ ឱ្យបាន ឱឡារិកអធិកអធមនៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ។

៣- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយថវិកាសំរាប់ការរៀបចំពិធីនេះ ។

៤- រាជរដ្ឋាភិបាលសូមអំពាវនាវដល់អង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋ សូមជួយឧបត្ថម្ភគាំទ្រ ដល់កម្មវិធីនេះអោយបានផុសផុល និងអធិកអធម ។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ត្រូវរៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធិភាពខ្ពស់ ។

*រាជធានីភ្នំពេញ . ថ្ងៃទី១៤ ខែ ឧសភា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល " ដើម្បីជូនជ្រាប "
- គ្រប់ក្រសួង-ស្ថាប័ន " ដើម្បីសហការអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ